

# របៀបប្រើប្រាស់សេវាកម្មរបស់យើង

rtd-denver.com | 303.299.6000 | customercare@rtd-denver.com

ក្នុងនាមជាអ្នកផ្តល់សេវាដឹកជញ្ជូនសាធារណៈសម្រាប់តំបន់ទីប្រជុំជន Denver ទីភ្នាក់ងារ RTD ធ្វើការតភ្ជាប់សហគមន៍ជាមួយរថយន្តក្រុង រថភ្លើង សេវា Access-a-Ride (សេវាកម្មសម្រាប់បុគ្គលដែលមានពិការភាព) សេវាដឹកជញ្ជូនទៅមកនៅក្នុងតំបន់ ដូចជា FlexRide និងជាច្រើនទៀត។ អនុញ្ញាតឱ្យ RTD ជួយបំពេញតម្រូវការការដឹកជញ្ជូនរបស់អ្នក!

## កម្មវិធីបញ្ចុះតម្លៃលើថ្លៃសំបុត្រធ្វើដំណើរ

អ្នកនិងគ្រួសាររបស់អ្នក អាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានការបញ្ចុះតម្លៃ។ ការបញ្ចុះតម្លៃលើថ្លៃសំបុត្រធ្វើដំណើរមានផ្តល់ជូនដល់៖

| | | | |
|---|---|---|---|
| **បុគ្គលដែលមានប្រាក់ចំណូលទាប** | **មនុស្សចាស់** (អាយុ 65+) | **បុគ្គលដែលមានពិការភាព** | **យុវជន** (អាយុ 19 ឆ្នាំចុះក្រោម)* |

**ស្វែងយល់បន្ថែមអំពីសិទ្ធិទទួលបាន និងធ្វើការដាក់ពាក្យស្នើសុំការបញ្ចុះតម្លៃលើថ្លៃសំបុត្រធ្វើដំណើរតាមរយៈគេហទំព័រ rtd-denver.com/discount-fares!**

* យុវជនដែលមានអាយុ ១៩ ឆ្នាំចុះក្រោម អាចធ្វើដំណើរ ដោយឥតគិតថ្លៃ អរគុណដល់កម្មវិធីការមិនគិតថ្លៃសំបុត្រធ្វើដំណើរសម្រាប់យុវជន (Zero Fare for Youth)។

## របៀបទិញសំបុត្រនិងប័ណ្ណធ្វើដំណើរ

មិនថាធ្វើដំណើរតាមរថយន្តក្រុង ឬតាមរថភ្លើងនោះទេ ការទិញសំបុត្រនិងប័ណ្ណធ្វើដំណើរ RTD របស់អ្នកគឺមានលក្ខណៈងាយស្រួល។ ជ្រើសរើសថ្លៃសំបុត្រធ្វើដំណើរដែលបំពេញតាមតម្រូវការរបស់អ្នក (3 ម៉ោង ប្រចាំថ្ងៃ ប្រចាំខែ) ហើយអ្នកអាចចាប់ផ្តើមការធ្វើដំណើររបស់អ្នកបានហើយ។

### កន្លែងទិញសំបុត្រនិងប័ណ្ណធ្វើដំណើរ

- ម៉ាស៊ីនលក់សំបុត្រនៅតាមគ្រប់ស្ថានីយ៍រថភ្លើង
- ប្រតិបត្តិកររថយន្តក្រុង (ប្រសិនបើប្រើសាច់ប្រាក់ សូមបង់តាមតម្លៃជាក់លាក់)
- នៅលើគេហទំព័រ rtdonlinestore.com
- បញ្ជរលក់សំបុត្ររបស់ RTD
- ហាងលក់ទំនិញ King Soopers និង Safeway ដែលចូលរួមជាមួយ

### RTD នៅលើទូរស័ព្ទស្មាតហ្វូនរបស់អ្នក

កន្លែងទិញសំបុត្រដែលងាយស្រួលបំផុត គឺទិញតាមទូរស័ព្ទស្មាតហ្វូនរបស់អ្នក។ ស្កែនកូដ QR នៅខាងស្តាំដៃ ដើម្បីទាញយកកម្មវិធី **RTD MyRide** សម្រាប់ប្រព័ន្ធប្រតិបត្តិការ IOS ឬ Android។




## រៀបគម្រោងជើងធ្វើដំណើររបស់អ្នក

ប្រើប្រាស់មុខងារ **Next Ride** របស់ RTD (app.rtd-denver.com/nextride)
ដើម្បីរៀបគម្រោងជើងធ្វើដំណើររបស់អ្នកតាំងពីដើមដល់ចប់ ពិនិត្យមើលដំណើរការរថយន្តក្រុងឬរថភ្លើងរបស់អ្នក ឬពិនិត្យមើលការពន្យារពេលឬការលុបចោលការធ្វើដំណើរបានភ្លាមៗ។

**ស្វែងយល់អំពីសេវាកម្ម RTD រៀបគម្រោងជើងធ្វើដំណើររបស់អ្នក និងអ្វីៗជាច្រើនទៀត ដោយចូលទៅកាន់គេហទំព័រ rtd-denver.com។**

## ជិះរថយន្តក្រុង

**ដំបូន្មានដែលមានប្រយោជន៍**

- មកដល់ចំណតរបស់អ្នកឱ្យបានមុនម៉ោង។
- នៅពេលដែលរថយន្តក្រុងមកដល់ ពិនិត្យមើលសញ្ញាប្រាប់ដំណឹងឌីជីថលនៅផ្នែកខាងលើខាងមុខរថយន្តក្រុង ដើម្បីប្រាកដថាវាជាផ្លូវធ្វើដំណើរនិងគោលដៅដែលអ្នកត្រូវការ!
- ឡើងជិះរថយន្តក្រុង ហើយបង់ថ្លៃសំបុត្រធ្វើដំណើររបស់អ្នកដោយប្រើលុយរាយ សំបុត្រដែលមានសុពលភាព ប័ណ្ណធ្វើដំណើរ កាត MyRide ឬសំបុត្រលើទូរស័ព្ទស្មាតហ្វូន។
- ប្រសិនបើប្រើកាត MyRide ឬសំបុត្រលើទូរស័ព្ទស្មាតហ្វូន សូមស្កែនវាដោយប្រើម៉ាស៊ីនពិនិត្យសុពលភាព។
- នៅពេលជិតដល់គោលដៅ សូមទាញខ្សែពណ៌លឿង ឬចុចប៊ូតុងដើម្បីសុំឈប់។
- សូមចុះតាមទ្វារខាងក្រោយប្រសិនបើអាចធ្វើបាន។




## ជិះរថភ្លើង

**ដំបូន្មានដែលមានប្រយោជន៍**

- សូមមកដល់ស្ថានីយ៍។ ពិនិត្យមើលសញ្ញាប្រាប់ដំណឹងឌីជីថល ឬមុខងារ Next Ride ដើម្បីមើលរថភ្លើងបន្ទាប់។
- ទិញសំបុត្រឬប័ណ្ណធ្វើដំណើរតាមម៉ាស៊ីនលក់សំបុត្រ ឬត្រៀមសំបុត្រ ឬកាតធ្វើដំណើរលើទូរសព្ទរបស់អ្នកឱ្យបានរួចរាល់មុនពេលឡើងជិះរថភ្លើង។
- បញ្ជាក់សុពលភាពសំបុត្រដែលបានព្រីនចេញនៅលើម៉ាស៊ីន "V" ពណ៌ក្រហម បញ្ជាក់សុពលភាពកាត MyRide របស់អ្នកនៅលើម៉ាស៊ីនបញ្ជាក់សុពលភាពពណ៌ខ្មៅលាយទឹកប្រាក់ ឬដំណើរការសំបុត្រលើទូរស័ព្ទរបស់អ្នក។ អ្នកមិនចាំបាច់ត្រូវបញ្ជាក់សុពលភាពការទិញសំបុត្រពីម៉ាស៊ីនលក់សំបុត្រនោះទេ។
- ឈរខាងក្រោយបន្ទាត់ពណ៌លឿង ដើម្បីរង់ចាំរថភ្លើង។
- មើលសញ្ញាប្រាប់ដំណឹងឌីជីថល ឬស្តាប់ការប្រកាសតាមឧគ្ឃោសនាសព្ទ ដើម្បីដឹងថាពេលណាអ្នកជិតទៅដល់គោលដៅរបស់អ្នក។




## រក្សាសុវត្ថិភាពនៅលើរថយន្តក្រុងនិងរថភ្លើង




ប្រសិនបើឃើញមានអ្វីមិនស្រួល សូមនិយាយ។ ស្កែនកូដ QR នៅខាងឆ្វេងដៃដើម្បីទាញយកកម្មវិធី **Transit Watch** របស់ RTD ដើម្បីរាយការណ៍អំពីការព្រួយបារម្ភអំពីសុវត្ថិភាពនិងសន្តិសុខនៅលើ ឬជុំវិញប្រព័ន្ធរបស់ RTD។ អ្នកក៏អាចទូរស័ព្ទទៅកាន់លេខ 303.299.2911 ឬផ្ញើសារជាអក្សរទៅកាន់លេខ 303.424.9100 បានផងដែរ ដើម្បីរាយការណ៍អំពីការព្រួយបារម្ភអំពីសន្តិសុខ។ សូមចូលទៅកាន់គេហទំព័រ rtd-denver.com/transitwatch ដើម្បីស្វែងយល់បន្ថែម។

## ការជួយ និងជំនួយផ្នែកភាសា

ទូរស័ព្ទទៅកាន់ផ្នែកថែទាំអតិថិជន តាមរយៈលេខ 303.299.6000 ដើម្បីសួរសំណួរអំពី RTD។ សេវាបកប្រែផ្ទាល់មាត់មានផ្តល់ជូនដោយឥតគិតថ្លៃជាង **200 ភាសា**។ សម្រាប់ភាសាអេស្ប៉ាញ សូមចុចលេខ 2។ សម្រាប់ភាសាផ្សេងទៀត សូមចុចលេខ 8។ បន្ទាប់មក សូមប្រាប់ភ្នាក់ងារថាអ្នកនិយាយភាសាអ្វី ហើយសូមបន្តការចាប់ទូរស័ព្ទរង់ចាំ ខណៈពេលពួកគេកំពុងភ្ជាប់អ្នកទៅកាន់អ្នកបកប្រែ។

**ស្វែងយល់អំពីសេវាកម្ម RTD រៀបគម្រោងដើរធ្វើដំណើររបស់អ្នក និងអ្វីៗជាច្រើនទៀត ដោយចូលទៅកាន់គេហទំព័រ rtd-denver.com។**